MEKONG RIVER COMMISSION
MRC
FOR SUSTAINABLE DEVELOPMENT

# គណៈកម្មការទន្លេមេគង្គ

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅភ្នំពេញ**
ផ្ទះលេខ ៥៧៦ ផ្លូវជាតិលេខ ២ សង្កាត់ចាក់អង្រែក្រោម
ប្រអប់សំបុត្រលេខ ៦២៣ ទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខ ៨៥៥-២៣ ៤២៥ ៣៥៣.
ទូរសារលេខ ៨៥៥-២៣ ៤២៥ ៣៦៣

**ការិយាល័យលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គនៅវៀងច័ន្ទ**
ការិយាល័យប្រធានលេខាធិការដ្ឋាន គណៈកម្មការទន្លេមេគង្គ
អគារលេខ ១៨៤ ផ្លូវហ្វា ងុម សាធារណៈរដ្ឋប្រជាធិបតេយ្យ
ប្រជាមានិតឡាវ ប្រអប់សំបុត្រលេខ ៦១០១ ទីក្រុងវៀងច័ន្ទ ០១០០០
ទូរស័ព្ទលេខ ៨៥៦-២១ ២៦៣ ២៦៣
ទូរសារលេខ ៨៥៦-២១ ២៦៣ ២៦៤

## ព័ត៌មានសំរាប់ប្រព័ន្ធផ្សព្វផ្សាយ

ថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ២០១០

## គណៈកម្មការទន្លេមេគង្គ ទទួលបានការជូនដំណឹងជាលើកទីមួយ អំពីគំរោងសាងសង់វារីអគ្គិសនី សាយ៉ាបួរីនៅលើទន្លេមេនៃទន្លេមេគង្គ

*ទីក្រុងវៀងច័ន្ទ សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ*

គណៈកម្មការទន្លេមេគង្គ ទទួលបានការជូនដំណឹងជាផ្លូវការពីរដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតឡាវ អំពីគំរោងស្នើអភិវឌ្ឍន៍វារីអគ្គិសនីសាយ៉ាបួរីនៅលើទន្លេមេនៃទន្លេមេគង្គ។ គំរោងអភិវឌ្ឍន៍វារីអគ្គិសនីសាយ៉ាបួរី នឹងជាគំរោងទំនប់វារីអគ្គិសនីទីមួយនៅលើទន្លេមេនៃទន្លេមេគង្គក្រោម ដែលនឹងអាចផលិតថាមពលអគ្គិសនីបាន ១២៦០ មេហ្គាវ៉ាត់ ភាគច្រើនសំរាប់លក់ចេញទៅព្រះរាជាណាចក្រថៃ។ គំរោងអភិវឌ្ឍន៍វារីអគ្គិសនីសរុបចំនួន ៦ ត្រូវបានស្នើឡើងនៅតាមទន្លេមេនៃទន្លេមេគង្គ ចាប់ខេត្តចៀងសែននៅព្រះរាចាណាចក្រថៃ មកដល់ខេត្តវៀងច័ន្ទនៃសាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ បើទោះបីជាប្រទេសសមាជិកទន្លេមេគង្គបានទទួលព័ត៌មានដំណាក់កាលដំបូងអំពីគំរោងអភិវឌ្ឍន៍វារីអគ្គសនីសាយ៉ាបួរីនេះរួចហើយក៏ដោយ ការជូនដំណឹងពេលនេះ នឹងនាំទៅដល់ការអនុវត្តជាលើកទីមួយនូវនីតិវិធីរបស់គណៈកម្មការទន្លេមេគង្គស្តីអំពីការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (Procedures for Notification, Prior Consultation and Agreement, PNPCA) ។

លោក ដេរីមី ប៊ីត ប្រធានប្រតិបត្តិនៃលេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ និយាយថា "ដំណើរការនៃការពិគ្រោះយោបល់ជាមុន គឺជាតំរូវការមួយរបស់កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ ដែលទាមទារអោយប្រទេសសមាជិកធ្វើការពិនិត្យឡើងវិញរួមគ្នាទៅលើទំនប់វារីអគ្គិសនីណាមួយស្នើសាងសង់នៅតាមទន្លេមេនៃទន្លេមេគង្គ ប្រយោជន៍ដើម្បីឈានដល់កិច្ចព្រមព្រៀងមួយថាតើគួរសាងសង់ ឬមិនគួរ ហើយបើត្រូវសាងសង់ដូចដែលស្នើឡើង តើត្រូវអនុវត្តតាមល័ក្ខខ័ណ្ឌអ្វីខ្លះ។" លោកដេរីមីបន្ថែមទៀតថា "យើងរំពឹងថាការវិភាគលំអិតនៃបញ្ហាពាក់ព័ន្ធទាំងអស់ ហើយនិងការសំរេចចិត្តណាមួយរបស់ប្រទេសសមាជិក នឹងទាមទាររយៈពេលប្រហែល៦ខែ។"

កិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ បានបង្កើតអោយមាននីតិវិធីសំរាប់កាជូនដំណឹងការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ដែលចែងថាប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គត្រូវតែជូនដំណឹងដល់គណៈកម្មាធិការរួមរបស់គណៈកម្មការទន្លេមេគង្គ នៅពេលដែលប្រទេសសមាជិកចង់អនុវត្តគំរោងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធទ្រង់ទ្រាយធំណាមួយ (ដូចជាគំរោងសាងសង់ទំនប់វារីអគ្គិសនីជាដើម) នៅលើទន្លេមេនៃទន្លេមេគង្គ ឬក៏នៅតាមដៃទន្លេមេគង្គ ជាពិសេសប្រសិនបើការអភិវឌ្ឍទាំងនោះនាំអោយមានផលប៉ះពាល់ឆ្លងប្រទេសទៅលើជីវភាពប្រជាជន និងបរិស្ថាននៅតាមផ្នែកខាងក្រោមទន្លេ។

គំរោងសាងសង់ទំនប់វារីអគ្គិសនីសាយ៉ាបួរី គឺគ្រាន់តែជាគំរោងមួយ ក្នុងចំណោមគំរោងអភិវឌ្ឍន៍១២ ប៉ុណ្ណោះដែលត្រូវបានស្នើឡើងនៅលើទន្លេមេនៃទន្លេមេគង្គ។ កាលពីឆ្នាំទៅគណៈកម្មកាទន្លេមេគង្គ បានជួលកុងស៊ុលតង់មួយក្រុមដើម្បីធ្វើការប៉ាន់ប្រមាណផ្នែកបរិស្ថានជាយុទ្ធសាស្ត្រទៅលើគំរោងវារីអគ្គិសនីទាំងអស់ដែលត្រូវបានស្នើសាងសង់នៅតាមទន្លេមេ

នៃទន្លេមេគង្គរួមទាំងការប៉ាន់ប្រមាណលើផលប៉ះពាល់នៃទំនប់វារីអគ្គិសនីដែលប្រទេសចិនបានសាងសង់រួច និងទំនប់វារីអគ្គិសនីគ្រោងសាង់សង់នៅតាមទន្លេមេគង្គលើ។

លោក ដេរីមី ប៊ីត និយាយថា "ការប៉ាន់ផ្នែកបរិស្ថានជាយុទ្ធសាស្ត្រ គឺជាផ្នែកមួយនៃការត្រៀមរៀបចំរបស់គណៈកម្មការទន្លេមេគង្គសំរាប់ដំណើរការនៃការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)ហើយរបាយការណ៍ចុងក្រោយនៃការប៉ាន់ផ្នែកបរិស្ថានជាយុទ្ធសាស្ត្រ នឹងត្រូវផ្សព្វផ្សាយជាសាធារណៈនៅចុងខែកញ្ញានេះ។ ការប៉ាន់ប្រមាណផ្នែកបរិស្ថានជាយុទ្ធសាស្ត្រ នឹងផ្តល់នូវក្របខ័ណ្ឌសំរាប់ការវិភាគជាចាំបាច់ទៅលើ

ផលប្រយោជន៍ ការចំណាយ និងផលប៉ះពាល់របស់គំរោងអភិវឌ្ឍន៍ទាំងអស់ព្រមទាំងព័ត៏មានអំពី ការបែងចែកចំណាយ និងផលប្រយោជន៍។”

លោកនិយាយបន្ថែមថា “ការប៉ាន់ប្រមាណផ្នែកបរិស្ថានជាយុទ្ធសាស្រ្ត គឺជាសិក្សាមួយ ក្នុងការសិក្សាដ៏ទូលំទូលាយជាច្រើន ហើយនឹងត្រូវបញ្ចប់រួចរាល់ទាន់ពេលដើម្បីប្រើជាព័ត៏មានសំរាប់ ការពិភាក្សាដោយប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គអំពីគំរោងសាងសង់ទំនប់វារីអគ្គិសនី សាយ៉ាបូរី តាមរយៈដំណើរការនៃនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង ( PNPCA)។”

គណៈកម្មការទន្លេមេគង្គ និយាយថា ដំណើរការនៃការអនុវត្តនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA) ជាយន្តការផ្លូវការមួយដែលត្រូវបាន បង្កើតឡើង ដើម្បីអនុញ្ញាតអោយប្រទេសមួយ ឬច្រើននៃប្រទេសសមាជិកគណៈកម្មការទន្លេមេគង្គ ដាក់ជូនគំរោងអភិវឌ្ឍន៍សំរាប់ការពិចារណាថ្នាក់តំបន់ដោយប្រទេសសមាជិកទាំងបួន។

ចំពោះករណីគំរោងវារីអគ្គិសនីសាយ៉ាបូរី រដ្ឋាភិបាលសាធារណៈរដ្ឋប្រជាមានិតឡាវ បានជូនដំណឹងដល់គណៈកម្មការទន្លេមេគង្គ ដើម្បីចាប់ផ្តើមដំណើរការនៃនីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)។ នៅក្នុងកំឡុងពេលនៃដំណើរការ នីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)នេះ

គណៈកម្មាធិការរួមរបស់គណៈកម្មការទន្លេមេគង្គដែលរួមមានតំណាងមកពីប្រទេសសមាជិកទាំងបួន នឹងពិគ្រោះគ្នា ដើម្បីព្យាយាម និងដើម្បីឈានទៅព្រមព្រៀងគ្នាលើជំហររួមមួយលើការអភិវឌ្ឍ ទំនប់វារីអគ្គិសនីដែលត្រូវបានស្នើឡើង។ ដំណើរការពិគ្រោះយោបល់នេះ ជាពិធីការមួយ ក្នុងចំណោមពិធីការមួយចំនួនចែងនៅក្នុងកិច្ចព្រមព្រៀងទន្លេមេគង្គឆ្នាំ ១៩៩៥ ដើម្បីជំរុញ កិច្ចសហប្រតិបត្តិការនៅក្នុងការគ្រប់គ្រងដោយនិរន្តរភាពនៃធនធានទឹកទន្លេមេគង្គ និងដើម្បីចៀសវាង កុំអោយមានវិវាទក្នុងតំបន់កើតឡើង។

ដូចដែលតំរូវអោយមានចំពោះគំរោងហេដ្ឋារចនាសម្ព័ន្ធធំដទៃ១ទៀត ដំណើរការនៃ នីតិវិធីជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង នឹងតំរូវអោយមានការពិចារណា និងថ្លឹងថ្លែងរវាងផលប្រយោជន៍ និងផលប៉ះពាល់។ តួនាទីមួយរបស់ការប៉ាន់ប្រមាណផ្នែកបរិស្ថាន

ជាយុទ្ធសាស្ត្រ គឺការពិនិត្យមើលទៅលើវិសាលភាពដែលគេអាចចៀសវាង កាត់បន្ថយ និងដោះស្រាយផលប៉ះពាល់អវិជ្ជមាន។ គណៈកម្មាធិការរួមរបស់គណៈកម្មការទន្លេមេគង្គ នឹងពិចារណាទៅលើសំណើរបស់ក្រុមហ៊ុនអភិវឌ្ឍន៍ដោយផ្ទៀងផ្ទាត់ជាមួយនឹងចំណុចទាំងអស់នេះ មុននឹងឈានទៅធ្វើសេចក្តីសំរេចណាមួយ។

រហូតមកទល់នឹងពេលនេះ គំរោងអភិវឌ្ឍន៍វារីអគ្គិសនីមួយចំនួននៅតាមដៃទន្លេមេគង្គ ត្រូវបានពិចារណាក្រោមដំណើរការនៃនីតិវិធីសំរាប់ការជូនដំណឹង ការពិគ្រោះយោបល់ជាមុន និងការព្រមព្រៀង (PNPCA)នេះ ប៉ុន្តែគំរោងស្នើសាងសង់នៅលើទន្លេមេនៃទន្លេមេគង្គ ទាមទារអោយមានការជជែកគ្នាច្រើនជាងមុនដោយស្ថាប័នកំរិតខ្ពស់ជាងមុនមកពីប្រទេសសមាជិកទាំងបួនតាមរយៈដំណើរការ “ពិគ្រោះយោបល់ជាមុន”មុននឹងការអនុម័តផ្លូវច្បាប់របស់ប្រទេសណាមួយត្រូវបញ្ចប់។ ការបែងចែកភាពខុសគ្នានេះ ឆ្លុះបង្ហាញពីការទាមអោយមានការសិក្សាអោយបានកាន់តែទូលំទូលាយទៅលើផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានដែលអាចកើតមានដោយសារទំនប់វារីអគ្គិសនីស្នើនៅតាមទន្លេមេនៃទន្លេមេគង្គ ជាពិសេសផលប៉ះពាល់ទៅលើការធ្វើបំលាស់ទីរបស់ត្រី និងជីវភាពរស់នៅរបស់ប្រជាជន។

**កំណត់សំគាល់បន្ថែមសំរាប់និពន្ធនាយក:**

ទំនប់វារីអគ្គិសនីសាយ៉ាបួរី ស្ថិតនៅចំងាយប្រមាណ ១៥០ គីឡូម៉ែត្រពីទីក្រុងហ្លួងប្រាបាង នៅភាគខាងជើងនៃសាធារណៈរដ្ឋប្រជាមានិតឡាវ។ ទំនប់នេះ មានសមត្ថភាពផលិតថាមពលអគ្គិសនីបានចំនួន ១២៦០ មេហ្កាវ៉ាត់ ដោយមានប្រវែង ៨១០ម៉ែត្រ មានកំពស់ ៣២ម៉ែត្រ និងទំហំអាងស្តុកទឹកប្រវែង ៩២ គីឡូម៉ែត្រការ៉េ ហើយនិងស្តុកទឹកបានទំហំ ២២៥ លានម៉ែត្រគូប។ ភាគច្រើននៃអគ្គិសនីដែលផលិតបាននឹងត្រូវលក់អោយទៅព្រះរាជាណាចក្រថៃ។ គោលដៅចំបងនៃទំនប់វារីអគ្គិសនីនេះ គឺដើម្បីបង្កើនចំណូលរូបិយប័ណ្ណបរទេសសំរាប់ចំណាយលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងសង្គមនៅក្នុងសាធារណៈរដ្ឋប្រជាមានិតឡាវ។ ក្រុមហ៊ុនអភិវឌ្ឍន៍ មានឈ្មោះ *Ch. Karnchang Public Co. Ltd.* របស់ព្រះរាជាណាចក្រថៃដែលបានចរចារអោយមានកិច្ចព្រមព្រៀងលើពន្ធនាំចូលជាមួយអាជ្ញាធរផលិតថាមពលអគ្គិសនីរបស់ព្រះរាជាណាចក្រថៃ *(Electricity Generating Authority of Thailand, EGAT)* កាលពីខែកក្កដា ឆ្នាំ ២០១០។

គណៈកម្មការទន្លេមេគង្គ ជាស្ថាប័នអន្តររដ្ឋាភិបាល របស់ព្រះរាជាណាចក្រកម្ពុជា សាធារណៈរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ព្រះរាជាណាចក្រថៃ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម។ គណៈកម្មការទន្លេមេគង្គ មានភារៈកិច្ចទទួលខុសត្រូវចំពោះកិច្ចប្រតិបត្តិការលើការគ្រប់គ្រងលើអាងទន្លេមេគង្គ ប្រកបដោយនិរន្តរភាព។ គណៈកម្មការទន្លេមេគង្គ ធ្វើការងារលើវិស័យផ្សេងៗដែលពាក់ព័ន្ធនឹងទន្លេ ក្នុងនោះរួមមានការគ្រប់គ្រងជលផលប្រកបដោយនិរន្តរភាព ការស្វែងរកកាលានុវត្តភាពសំរាប់ការអភិវឌ្ឍវិស័យកសិកម្ម ការអភិវឌ្ឍវារីអគ្គិសនីប្រកបដោយនិរន្តរភាព និងការរក្សាអោយបាននូវសេរីភាពនាវាចរណ៍ ការគ្រប់គ្រងទឹកជំនន់ និងអភិរក្សប្រព័ន្ធអេកូឡូស៊ី។ បន្ថែមលើវិស័យផ្សេងៗខាងលើ គឺឥទ្ធិពលនៃទឹកជំនន់ធំៗ គ្រោះរាំងស្ងួតរយៈពេលយូរច្រើនជាងមុន និងការកើនឡើងនូវកំរិតទឹកសមុទ្របង្ករឡើងដោយការប្រែប្រួលអាកាសធាតុ។ គណៈកម្មការទន្លេមេគង្គ ផ្តល់ជាវេទិកាសម្រាប់... 

**សំរាប់ព័ត៌មានបន្ថែម** សូមទាក់ទងមកអ្នកស្រី ទីហ្វានី ហាក់គ័រ ទីប្រឹក្សាស្តីទីផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈអ៊ីមែល damian@mrcmekong.org ទូរស័ព្ទលេខ (៨៥៦-២០) ៥៦១ ២០៦៩៥ (៨៥៦-២១) ២១ ២៦៣ ២៦៣ ឬ លោក លីម ឃី មន្រ្តីផ្នែកទំនាក់ទំនងរបស់លេខាធិការដ្ឋានគណៈកម្មការទន្លេមេគង្គ តាមរយៈអ៊ីមែល khy@mrcmekong.org ទូរស័ព្ទលេខ (៨៥៦-២០) ៥៥៥ ២៨៧២៦ វិបសាយ www.mrcmekong.org